DBD ENGINEERING

២០២៣




# ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

## របាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ត្រីមាសទី២ ឆ្នាំ ២០២៣ *(បានត្រួតពិនិត្យឡើងវិញ)* | ឆ្នាំ ២០២២ *(បានធ្វើសវនកម្មរួច)* |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | |
| ទ្រព្យសកម្មសរុប | | ៦៨.២២៣.១៣៦ | ៦០.៧៥១.៧៣១ |
| បំណុលសរុប | | ៣២.៧៩៣.៧១១ | ២៩.២៣៦.៣៩០ |
| មូលធនសរុប | | ៣៥.៤២៩.៤២៥ | ៣១.៥១៥.៣៤១ |
| **លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)** | | **ត្រីមាសទី២ ឆ្នាំ ២០២៣** *(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី២ ឆ្នាំ ២០២២** *(បានត្រួតពិនិត្យឡើងវិញ)* |
| ចំណូលសរុប | | ២៨.៦៣៩.៨៨០ | ១១.៩៧៤.៧៦៣ |
| ចំណេញ/(ខាត)មុនបង់ពន្ធ | | ២.០៩៩.២២៧ | (៣.៥៦០.៥៣៥) |
| ចំណេញសុទ្ធ/(ខាត)ក្នុងការិយបរិច្ឆេទ | | ១.៩៩៧.៦២៤ | (៣.៦៧៧.៦៩៨) |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១.៦៧៦.០៦២ | (៣.៦៨៦.៧៥៧) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី២ ឆ្នាំ ២០២៣** *(បានត្រួតពិនិត្យឡើងវិញ)* | **ឆ្នាំ ២០២២** *(បានធ្វើសវនកម្មរួច)* |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ១,៧៨ ដង | ១,៦៣ ដង |
| | អនុបាតចរន្តលឿន | ១,៦១ ដង | ១,៤៣ ដង |
| | | **ត្រីមាសទី២ ឆ្នាំ ២០២៣** *(បានត្រួតពិនិត្យឡើងវិញ)* | **ត្រីមាសទី២ ឆ្នាំ ២០២២** *(បានត្រួតពិនិត្យឡើងវិញ)* |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | ២,៤៦ | (៦,៩៧) |
| | អនុបាតចំណេញធៀបនឹងមូលធន (%) | ៤,៧៣ | (១០.៩០) |
| | អនុបាតគម្លាតចំណេញដុល(%) | ១៥,១៧ | (១៤,១៩) |
| | អនុបាតគម្លាតចំណេញភាព(%) | ៥,៨៥ | (៣០,៧៩) |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៩០ រៀល | (១៩០) រៀល |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ៥,៥៨ | (១០,៨១) |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

❖ ស្ថានភាពហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ (ពាន់រៀល)




❖ ចំណេញ/ (ខាត) ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ (ពាន់រៀល)




❖ បម្រែបម្រួលថ្លៃភាគហ៊ុនក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០២៣



## សមាសភាពក្រុមប្រឹក្សាភិបាល



**លោក នាង វិធី**

ប្រធានក្រុមប្រឹក្សាភិបាល
និង នាយកគ្រប់គ្រង



**លោក ថៃ វ៉ាន់ថា**

អភិបាលមិនប្រតិបត្តិ



**លោកស្រី លឹម មុយលី**

អភិបាលមិនប្រតិបត្តិ និង នាយកហិរញ្ញវត្ថុ



**លោក RAMI Bashir Asad Sharaf**

អភិបាលមិនប្រតិបត្តិ



**លោក ហ៊ុយ វ៉ាថារ៉ូ**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល



តំណាងអោយក្រុមហ៊ុន **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** និងជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ របស់យើងខ្ញុំ ដោយគិតចាប់ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៣ ជូនភាគីពាក់ព័ន្ធ និងសាធារណជនទាំងអស់។

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុនទទួលបាន**ប្រាក់ចំណូលសរុប** **២៨.៦៣៩.៨៨០ ពាន់រៀល** ដែលមានការ**កើនឡើង**ចំនួន **១៣៩,១៧%** បើធៀបនឹងប្រាក់ចំណូលសរុប ១១.៩៧៤.៧៦៣ ពាន់រៀល ក្នុងត្រីមាសទី២ ឆ្នាំ២០២២។ ដោយឡែក ក្រុមហ៊ុនទទួលបាន**ចំណេញលម្អិតក្នុងការិយបរិច្ឆេទ**ចំនួន **១.៦៧៦.០៦២ ពាន់រៀល** សម្រាប់ត្រីមាសនេះ ដែល**កើនឡើង**ចំនួន **១៤៥,៤៦%** បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២ ក្រុមហ៊ុនបានខាតលម្អិតក្នុងការិយបរិច្ឆេទ មានចំនួន ៣.៦៨៦.៧៥៧ ពាន់រៀល។ ទ្រព្យសកម្មសរុបកើនឡើង ១២,៣០% បើធៀបនឹងឆ្នាំ ២០២២ ដែលកើនពី ៦០.៧៥១.៧៣១ ពាន់រៀល ដល់ ៦៨.២២៣.១៣៦ ពាន់រៀល។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក សម្រាប់ដំបូន្មានល្អៗ និងការខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់គ្នា សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះនិយ័តករមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលផ្តល់ទំនុកចិត្ត និងការគាំទ្រដល់ក្រុមហ៊ុន ឌី ប៊ី ឌី។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING
Plc.
KINGDOM OF CAMBODIA

**លោក នាង វីធី**

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

## មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ...... ii

**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ...... iii

**សមាសភាពក្រុមប្រឹក្សាភិបាល** ...... iv

**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ...... v

**ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ...... 1

ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ...... 1

ខ-លក្ខណៈនៃធុរកិច្ច ...... 2

គ-ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ...... 3

**ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ...... 5

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ...... 5

ខ-រចនាសម្ព័ន្ធចំណូល ...... 7

**ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ...... 9

**ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ...... 10

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ...... 10

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ...... 12

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ...... 13

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ...... 14

ង-ផលប៉ះពាល់នៃអតិផរណា ...... 14

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ...... 14

**ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ...... 16

**ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

### ក-អត្តសញ្ញាណរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ( ឌី ប៊ី ឌី ) |
| ជាអក្សរឡាតាំង | DBD Engineering Plc. |
| អក្សរកូដ | KH១០០០១៩០០០៨ |
| ទីស្នាក់ការ | ដីឡូត៍ ១២៩៨ ផ្លូវ បេតុង ភូមិស្វាយចេក សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរសព្ទ | (+៨៥៥) ៧៨ ៧០០ ៥៩៨ |
| គេហទំព័រ | www.dbdengineering.com |
| អ៊ីម៉ែល | services@dbdengineering.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៤០២៩ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៨ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ១២៣/២១ ស.ស.រ/ន.ម.ក. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ |
| ឈ្មោះបុគ្គលតំណាងក្រុមហ៊ុន | លោក **នាង វិធី** |





## ខ-លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារ ផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី បី ឌី ផ្តល់សេវាកម្មដូចជា សេវាគូសប្លង់ សាងសង់ដំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឱ្យក្រុមហ៊ុនទទួលកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌី បី ឌី ទទួលបានកំណត់ត្រាល្អក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាពខ្ពស់ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។

អគ្គិសនី និងសំណង់



មេកានិច និងអគ្គិសនី



ការចុះត្រួតពិនិត្យ និងថែទាំអគារ



កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់



ឌី បី ឌី មានបុគ្គលិកជំនាញផ្នែកសេវាកម្ម និងការថែទាំ ដើម្បីធានា និងរក្សាគុណភាពជាប់រឹងមាំរបស់សំណង់អគារ និងការបំពាក់ឧបករណ៍ថ្មី ហើយបច្ចុប្បន្ននេះ ឌី បី ឌី បាន និងកំពុងពង្រីកអាជីវកម្មផ្នែក ផលិតកម្មលើប្រព័ន្ធបំពង់ គ្រឿងចក្រ ការថែរក្សារោងចក្រ និងឧបករណ៍។

## គ-ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក




ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី បានរៀបចំពិធីបញ្ចុះបឋមសិលាបើកការដ្ឋានថ្មីគឺ គម្រោងសាងសង់រោងចក្រថ្មីរបស់ក្រុមហ៊ុន OJI Packaging (Cambodia) Co., LTD ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលក្រុមហ៊ុន ឌី ប៊ី ឌី ទទួលខុសត្រូវទាំងមូលនៅក្នុងគម្រោងនេះ។






ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២ ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងវិនិយោគិន ចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ Zoom។














ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី បាន រៀបចំកិច្ចប្រជុំដំបូង និងចុះត្រួតពិនិត្យដល់ទីកន្លែងមុននឹងចាប់ផ្ដើមគម្រោងថ្មីគឺ ការងារខាងក្រៅសម្រាប់ការសាងសង់ព្រលានយន្តហោះអន្តរជាតិតេជោ



## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

នាដើមឆ្នាំ២០២២ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានគម្រោងដំបូងគេ គឺការសាងសង់ និងដំឡើងប្រព័ន្ធ MEP របស់អាគារ "WING OFFICE TOWER" ដែលមានទីតាំងស្ថិតនៅមហាវិថីព្រះមុនីវង្ស និងមហាវិថីកម្ពុជាក្រោម ក្នុងសង្កាត់មនោរម្យ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ។ គម្រោងនេះបានចាប់ផ្តើមធ្វើការសាងសង់ក្នុងឆ្នាំ ២០២២ និង បញ្ចប់គម្រោងក្នុងឆ្នាំ ២០២៣ នាពេលខាងមុខ។ បន្ថែមពីនេះក្រុមហ៊ុន ឌី ប៊ី ឌី ក៏សម្រេចទទួលយកគម្រោងធំមួយ ទៀតខាងផ្នែកសាងសង់ទាំងមូលទៅលើ គម្រោង "BIOMASS STEAM BOILER PLANT" ពីខាងក្រុមហ៊ុន BECIS ដែលនឹងផលិតថាមពលដោយចំហាយ និងផ្គត់ផ្គង់ទៅអោយ ក្រុមហ៊ុន HEINEKEN ។

ជាមួយគ្នានេះ ក្រុមហ៊ុន ឌី ប៊ី ឌី បានចូលរួមសាងសង់ និងបន្តសាង់សង់គម្រោងធំៗមានដូចជា ផ្សារទំនើបអ៊ីអនទី១, ផ្សារទំនើបអ៊ីអនទី២, គម្រោងខុនដូ North Park, គម្រោង ជីប ម៉ុង សែនសុខ, គម្រោងផ្សារទំនើប ជីប ម៉ុង ៥៩៨, និងគម្រោងផ្សារទំនើប ជីប ម៉ុង ២៧១ ជាដើម។

បច្ចុប្បន្នក្រុមហ៊ុនកំពុងធ្វើការលើប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងធនធានមនុស្សដែលជួយឱ្យអ្នកគ្រប់គ្រងទទួលបានរបាយ-ការណ៍ផ្ទាល់កាន់តែងាយស្រួលលើការរៀបចំ និងការត្រួតពិនិត្យកម្លាំងពលកម្ម ដើម្បីកាត់បន្ថយការខ្វះខាតកម្លាំង ពលកម្ម។ បន្ថែមពីនេះ ក្រុមហ៊ុនក៏អនុវត្តមុខងារថ្មីនៅក្នុងប្រព័ន្ធគណនេយ្យបច្ចុប្បន្នផងដែរ ដើម្បីគ្រប់គ្រងការថ្លៃដើម សម្ភារៈ។

### គម្រោងថ្មី នៃត្រីមាសទី២ ឆ្នាំ២០២៣

| គម្រោង | ចំនួនទឹកប្រាក់ (រួមបញ្ចូលពន្ធ) | កាលបរិច្ឆេទរំពឹងទុកនៃការបញ្ចប់គម្រោង |
|---|---|---|
| External Work for Techo International Airport | ៧.៦០០.០០០ ដុល្លារអាមេរិក | ១២ មករា ២០២៤ |

### គម្រោងស្ថិតក្នុងដំណើរការ

| គម្រោង | កាលបរិច្ឆេទចាប់ផ្តើមគម្រោង | លទ្ធផលសម្រេចបាន |
|---|---|---|
| Chip Mong 271 Mega Mall | កក្កដា ២០២០ | ៩៩,៩៥% |
| WING Tower | ០៦ មករា ២០២២ | ៩៧,១៥% |
| Wing Tower-ID Lighting | មករា ២០២២ | ៤២,០០% |
| WING Tower-LED Screen | មិថុនា ២០២២ | ៤២,០០% |

| | | |
|---|---|---|
| Tenant Cinema | ០៥ សីហា ២០២២ | ៩៩,២១% |
| Tenant CMG Office | ០៨ សីហា ២០២២ | ៩៩,០០% |
| Wing PBC 2 | ២១ មីនា ២០២៣ | ៨៥,០០% |
| B-Quick Aeon 3 | ២៧ មីនា ២០២៣ | ៧២,៦៧% |
| OJI Packaging | ១៧ ឧសភា ២០២៣ | ៩,០០% |




❖ គម្រោង BIOMASS STEAM BOILER PLANT




គម្រោងអាគារ WING OFFICE TOWER



គម្រោង CHIP MONG MEGA MALL 271




គម្រោង CHIP MONG SENSOK MALL




គម្រោង WING BANK



គម្រោង TRIBE HOTEL Phnom Penh

## ខ-រចនាសម្ព័ន្ធចំណូល

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានប្រភពចំណូលពីរ ដែលចំណូលទី ១ គឺបានមកពីគម្រោងសាងសង់ដែលជាប្រភពចម្បង ក្នុងនោះរួមបញ្ចូលនូវគម្រោងថ្មី និងការងារជួសជុល និងការថែទាំ។ ប្រភពចំណូលទី ២ គឺបានមកពីការលក់សម្ភារៈគម្រោង ដែលវាជាផ្នែកតូចមួយរបស់ចំណូលសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលពីការលក់សម្ភារៈគម្រោង នឹងមានការកើនឡើងបន្ទាប់ពីក្រុមហ៊ុនពង្រីកនូវផលិតកម្មបំពង់របស់ខ្លួន។ ក្រុមហ៊ុន ឌី ប៊ី ឌី នឹងធ្វើការលក់ផលិតផលនេះ ដែលសព្វថ្ងៃនេះក្រុមហ៊ុនផលិតសម្រាប់តែផ្គត់ផ្គង់គម្រោងសាងសង់របស់ខ្លួនប៉ុណ្ណោះ។

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ២០២៣ | | ត្រីមាសទី២ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ | ចំនួនទឹកប្រាក់ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីគម្រោងសាងសង់ | ២៨.៥៨៨.៩២០ | ៩៩,៨២% | ១១.៩០១.៧៧២ | ៩៩,៣៩% |
| ២ | ចំណូលពីការលក់ទំនិញ | ៥០.៩៦០ | ០,១៨% | ៧២.៩៩១ | ០,៦១% |
| ចំណូលសរុប | | **២៨.៦៣៩.៨៨០** | **១០០%** | **១១.៩៧៤.៧៦៣** | **១០០%** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលសរុបចំនួន ២៨.៦៣៩.៨៨០ ពាន់រៀល ដែលកើនឡើង ចំនួន ១៦.៦៦៥.១១៧ ពាន់រៀល ស្មើនឹង ១៣៩,១៧% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ ការកើនឡើងនេះ បណ្តាលមកពីចំណូលពីគម្រោងសាងសង់កើនឡើងចំនួន ១៤០,២១%។

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។

## ផ្នែកទី ៤.- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៣។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបានជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ឌី ប៊ី ឌី តែប៉ុណ្ណោះ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនម៉ៅការសាងសង់ឯកទេសផ្នែក MEP និងសំណង់ស៊ីវិល ដែលផ្តល់សេវាកម្មលើផ្នែកមេកានិច អគ្គិសនី ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ម៉ាស៊ីនត្រជាក់ បន្ទប់ត្រជាក់ HVAC និងថែទាំអគារ។

#### ១-ការវិភាគចំណូល

ប្រភពចំណូលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺបានពីសេវាសាងសង់ និងសេវាថែទាំ រួមទាំងការងារ MEP និងការងារសំណង់ស៊ីវិល ហើយចំណូលសរុបត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយធ្វើការបែងចែកជា ៣ (បី) ផ្នែកដូចជា៖ (១).ការសាងសង់ និងសេវាកម្មថែទាំ, (២).ការលក់ទំនិញ និង (៣).ចំណូលផ្សេងៗ។ ចំណូលត្រូវបានទទួលស្គាល់នៅពេលក្រុមហ៊ុន ឌី ប៊ី ឌី បានបំពេញការអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាអតិថិជនបានរួចរាល់។ ដើម្បីទទួលស្គាល់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី បានអនុវត្ត ៥ ជំហាន គឺ៖

១.កំណត់កិច្ចសន្យាជាមួយអតិថិជន

២.កំណត់ពីការអនុវត្តកាតព្វកិច្ច

៣.កំណត់ពីថ្លៃប្រតិបត្តិការ

៤.ការបែងចែកថ្លៃប្រតិបត្តិការធៀបនឹងការអនុវត្តកាតព្វកិច្ច

៥.ទទួលស្គាល់ចំណូលនៅពេល/ការអនុវត្តកាតព្វកិច្ចត្រូវបានពេញចិត្ត។

#### ២-ការវិភាគចំណូលតាមផ្នែក

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី មានចំណូលសរុបចំនួន ២៨.៦៣៩.៨៤០ ពាន់រៀល ដែលកើនឡើងចំនួន ១៦.៦៦៥.១១៧ ពាន់រៀល ស្មើនឹង ១៣៩,១៧% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ ការកើនឡើងនេះ បណ្តាលមកពីចំណូលពីគម្រោងសាងសង់កើនឡើងចំនួន ១៤០,២១%។

### ៣-ការវិភាគគម្លាតចំណេញដុល

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញដុលចំនួន ៤.៣៤៤.២៣២ ពាន់រៀល កើនឡើងចំនួន ៦.០៤៣.០៤២ ពាន់រៀល ស្មើនឹង ៣៥៥,៧២% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ ការកើនឡើងនៃចំណេញដុលនេះបណ្តាលមកពីការកើនឡើងនៃ ចំណូលសរុប និងថ្លៃដើមសេវា។

### ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេបប្រាក់ចំណេញ | ត្រីមាសទី២ ឆ្នាំ២០២៣ (ពាន់រៀល) | ត្រីមាសទី២ ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញដុល | ៤.៣៤៤.២៣២ | (១.៦៩៨.៨១០) | ៦.០៤៣.០៤២ | ៣៥៥,៧២% |
| ចំណូលផ្សេងៗ | ៣៣.៥២២ | ២០.៤០៦ | ១៣.១១៦ | ៦៤,២៨% |
| ចំណាយប្រតិបត្តិការ | (១.៨១៩.៧៤៦) | (១.៥៨០.៦២៧) | ២៣៩.១១៩ | ១៥,១៣% |
| ចំណាយហិរញ្ញវត្ថុ | (៤៥៨.៧៨១) | (៣០១.៥០៤) | ១៥៧.២៧៧ | ៥២,១៦% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២.០៩៩.២២៧** | **(៣.៥៦០.៥៣៥)** | **៥.៦៥៩.៧៦២** | **១៥៨,៩៦%** |

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មានចំណេញមុនបង់ពន្ធចំនួន ២.០៩៩.២២៧ ពាន់រៀល កើនឡើងចំនួន ៥.៦៥៩.៧៦២ ពាន់រៀល ស្មើនឹង ១៥៨,៩៦% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យចំណេញមានការកើនឡើង ដោយសារតែមានការកើនឡើងនូវ ចំណេញដុលចំនួន ៣៥៥,៧២% និងចំណូលផ្សេងៗចំនួន ៦៤,២៨%។

### ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ | ត្រីមាសទី២ ឆ្នាំ២០២៣ (ពាន់រៀល) | ត្រីមាសទី២ ឆ្នាំ២០២២ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | ២.០៩៩.២២៧ | (៣.៥៦០.៥៣៥) | ៥.៦៥៩.៧៦២ | ១៥៨,៩៦% |
| ចំណាយពន្ធលើប្រាក់ចំណូល | (១០១.៦០៣) | (១១៧.១៦៣) | (១៥.៥៦០) | -១៣,២៨% |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **១.៩៩៧.៦២៤** | **(៣.៦៧៧.៦៩៨)** | **៥.៦៧៥.៣២២** | **១៥៤,៣២%** |

ចំពោះពន្ធលើប្រាក់ចំណូល ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ត្រូវបង់ចំនួន ២០% នៃប្រាក់ចំណូលជាប់ពន្ធ ដោយកាត់កងជាមួយប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ចំនួន ១% នៃចំណូលប្រចាំឆ្នាំសរុប។

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានចំណេញក្នុងការិយបរិច្ឆេទចំនួន ១.៩៩៧.៦២៤ ពាន់រៀល កើនឡើងចំនួន ៥.៦៧៥.៣២២ ពាន់រៀល ស្មើនឹង ១៥៤,៣២% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យមានការកើនឡើងនៃប្រាក់ចំណេញនេះ គឺដោយសារមានការកើនឡើងនៃប្រាក់ចំណេញមុនបង់ពន្ធចំនួន ១៥៨,៩៦% និងមានការថយចុះនូវចំណាយពន្ធលើប្រាក់ចំណូលចំនួន ១៣,២៨%។

**៦-ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទទួលបានលទ្ធផលចំណេញលម្អិតក្នុងការិយបរិច្ឆេទចំនួន ១.៦៧៦.០៦២ ពាន់រៀល ដែលកើនឡើងចំនួន ៥.៣៦២.៨១៩ ពាន់រៀល ស្មើនឹង ១៤៥,៤៦% បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២២។ មូលហេតុចម្បងដែលធ្វើឱ្យមានការកើនឡើងនៃប្រាក់ចំណេញនេះ គឺដោយសារមានការកើនឡើងនៃប្រាក់ចំណេញដុលចំនួន ៣៥៥,៧២% ចំណេញមុនបង់ពន្ធចំនួន ១៥៨,៩៦% និងចំណេញក្នុងការិយបរិច្ឆេទចំនួន ១៥៤,៣២%។

**៧-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ**

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលគួរឱ្យកត់សម្គាល់ឡើយ។

## ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានវិភាគកត្តាសំខាន់ៗដូចខាងក្រោម ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពរកប្រាក់ចំណេញដល់ក្រុមហ៊ុន។

**១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់**

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទិន្នន័យសំណង់ទូទាំងប្រទេសមានចំនួន ៤.២៧៦ គម្រោង ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបចំនួន ៧.២៨៩.៧៦៥ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ ២.៩៧២.២៦០.៩២៨ ដុល្លារអាមេរិក មានការថយចុះចំនួន ៤៤,២៧ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៤.៣០៣ គម្រោង មានផ្ទៃក្រឡាកម្រាលសំណង់ចំនួន ១២.៩៩៨.០៧២ ម៉ែត្រការ៉េ ដែលមានតម្លៃប៉ាន់ស្មានទុនវិនិយោគប្រមាណ៥.៣៣៣.៧៩៨.៥២៥ ដុល្លារអាមេរិក។

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ (៣)កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ (៤) សំណង់ស៊ីវិល និង (៥) ការថែទាំអគារ។

### ២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនាវីង ម.ក បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើតម្លៃសម្ភារៈកើនឡើងខ្លាំង វានឹងធ្វើឱ្យក្រុមហ៊ុនខាតបង់។

### ៣-ការវិភាគលើពន្ធ

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនាវីង ម.ក បានទទួលនូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ៥០% សម្រាប់រយៈពេល៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០២២ ដល់ ២០២៤។ ដោយអនុលោមតាមច្បាប់ពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី ប៊ី ឌី មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% នៃប្រាក់ចំណូលជាប់ពន្ធ។ ក្រៅពីពន្ធលើប្រាក់ចំណេញ ក្រុមហ៊ុនក៏ត្រូវបង់ពន្ធអប្បបរមាផងដែរ។ ពន្ធអប្បបរមា ជាពន្ធប្រចាំឆ្នាំជាមួយនឹងអត្រា ១% លើចំណូលប្រចាំឆ្នាំសរុប ដោយរួមបញ្ចូលពន្ធគ្រប់ប្រភេទទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម និងដោយមិនគិតពីស្ថានភាពចំណេញ ឬខាតរបស់ក្រុមហ៊ុនឡើយ។ បន្ថែមពីនេះ ក្រុមហ៊ុនបានគណនាអាករលើតម្លៃបន្ថែមចំនួន ១០% នៅលើវិក័យបត្រដែលចេញទៅឱ្យអតិថិជន។ អាករលើតម្លៃបន្ថែម ត្រូវបានកាត់កងជាមួយអាករលើតម្លៃបន្ថែមលើធាតុចូល ១០% ដែលក្រុមហ៊ុនបានទូទាត់ទៅអ្នកផ្គត់ផ្គង់នូវរាល់ការទិញទំនិញ។ ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់នៅអត្រា ៤% នៃប្រាក់បញ្ញើចរន្ត ដែលត្រូវបានកាត់ទុកដោយធនាគារ, បង់ពន្ធកាត់ទុកលើប្រាក់បំណាច់ ឬលាភការរបស់ក្រុមប្រឹក្សាភិបាលនៅអត្រា ១៥%, បង់ពន្ធកាត់ទុកលើការចំណាយពាក់ព័ន្ធនឹងសេវាប្រឹក្សាយោបល់នៅអត្រា ១៤% (អនិវាសនជន) និងអត្រា ១៥% (និវាសនជន), និងបង់ពន្ធកាត់ទុកលើចំណូលពីការជួលនៅអត្រា ១០%។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏មានកាតព្វកិច្ចបង់ពន្ធលើការនាំចូលលើសម្ភារៈ និងវត្ថុធាតុដើមនូវអត្រា ៧% ទៅ ៣៥% ផ្អែកលើប្រភេទទំនិញ។

### ៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ គណៈគ្រប់គ្រងយល់ថាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ុនជីនាវីង ម.ក ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

## គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ប្រាក់ចំណូលរបស់ ឌី ប៊ី ឌី ពីការលក់សម្ភារៈមានការថយចុះយ៉ាងគួរឱ្យកត់សម្គាល់ ប៉ុន្តែប្រាក់ចំណូលពីការសាងសង់មានការកើនឡើង ដោយសារនៅក្នុងត្រីមាសនេះ ឌី ប៊ី ឌី បានបញ្ចប់គម្រោងមួយចំនួនដូចជា Tenant Market Place, Tenant Food Court, Tenant Paradise, Decathlon Aeon 3 និង Tenant CMRT Office។

ហើយនៅក្នុងត្រីមាសនេះ ឌី បី ឌី ក៏ទទួលបានគម្រោងថ្មីមួយចំនួន ដែលជាហេតុធ្វើឱ្យចំណូលមានការកើនឡើង បើធៀបទៅនឹងត្រីមាសទី២ នៃឆ្នាំ២០២២។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ១-ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេសផ្សេងទៀតទេ លើកលែងតែមានទឹកប្រាក់តូចមួយចំនួនសម្រាប់គណនីអ្នកផ្គត់ផ្គង់ ដែលត្រូវបង់ជារូបិយប័ណ្ណថៃបាត (THB) និង អឺរ៉ូ (EUR) ហើយរាល់កម្ចីទាំងអស់របស់ក្រុមហ៊ុនមានអត្រាថេរ  ដូច្នេះក្រុមហ៊ុនមិនមានផលប៉ះពាល់ខ្លាំងពីការប្រែប្រួលនៃការប្តូររូបិយបណ្ណបរទេស និងអត្រាការប្រាក់ទេ។

### ២-ផលប៉ះពាល់នៃអត្រាការប្រាក់

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក មិនទទួលរងហានិភ័យពាក់ព័ន្ធនឹងអត្រាការប្រាក់នោះទេ។

### ៣-ផលប៉ះពាល់នៃថ្លៃទំនិញ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក មិនមានផលប៉ះពាល់ជាសារវន្តលើថ្លៃទំនិញនោះទេ។

## ង-ផលប៉ះពាល់នៃអតិផរណា

ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ក្រុមហ៊ុន ឌី បី ឌី អ៊ិនជីនារីង ម.ក បានរួមបញ្ចូលការកើនឡើងនៃអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

## ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នៅក្នុងបរិបទអចលនទ្រព្យសកល ទីផ្សារកម្ពុជាគឺមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការរីកចម្រើនដ៏ឆាប់រហ័ស ក្នុងរយៈពេល ១០ (ដប់) ឆ្នាំចុងក្រោយនេះ។ យោងតាមរបាយការណ៍ពិនិត្យឡើងវិញប្រចាំឆមាសទី១ របស់ក្រុមហ៊ុន CBRE បានបញ្ជាក់ថា នាឆ្នាំ២០២៣ ទីផ្សារកម្ពុជាគឺជួបប្រទះផលប៉ះពាល់នៃការផ្លាស់ប្តូរម៉ាក្រូសេដ្ឋកិច្ចសកល ការថយចុះនៃតម្រូវការរបស់ប្រទេសចិន និងភាពលើសនៃការផ្គត់ផ្គង់តម្រូវការទីផ្សារ។ ការកើនឡើងនៃអតិផរណា  ធ្វើឱ្យការចំណាយទុនមានការកើនឡើងទ្វេដងព្រមទាំងការថយចុះនៃតម្រូវការពីប្រទេសភាគខាងលិច  បានធ្វើឱ្យមានផលប៉ះពាល់ផ្ទាល់លើការនាំចេញរបស់កម្ពុជា ដែលបណ្តាលឱ្យមានការធ្លាក់ចុះ ៣០% នៃការនាំចេញវាយនភណ្ឌ នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣។ តម្រូវការការិយាល័យជួលនៅក្នុងរាជធានីភ្នំពេញ គឺមានការរីកលូតលាស់យ៉ាងខ្លាំងនៅឆ្នាំ២០២៣ ដែលទំហំការិយាល័យត្រូវបានគេរំពឹងថាមានការកើនឡើងបន្ថែមប្រមាណ ២១៥.០០០ ម៉ែត្រការ៉េ។ អត្រាអ្នកជួលជាមធ្យមបានថយចុះពី ៦០% នៅត្រីមាសមុន ទៅ ៥៨% នៅឆមាសទី១ ឆ្នាំ២០២៣។ ខណៈការិយាល័យជួលដែលមាននៅទីតាំងពាណិជ្ជកម្ម និងទីតាំងមិនមែនពាណិជ្ជកម្ម បានកើនឡើង ចន្លោះពី ២% ទៅ ៤% គិតចាប់ពីឆមាសទី២ ឆ្នាំ២០២២។ បន្ទាប់ពីការរីកលូតលាស់

គួរឱ្យកត់សម្គាល់កាលពីប៉ុន្មានឆ្នាំកន្លងមក ទីផ្សារអចលនទ្រព្យលំនៅដ្ឋាន បានប្រឈមនឹងការលំបាកនាឆមាសទី១ ឆ្នាំ ២០២៣ ជាមួយនឹងការប្រកួតប្រជែងកាន់តែខ្លាំង និងមានការថយចុះនៃតម្រូវការ។ ខណៈដែលអគារខុនដូមួយចំនួន និងគម្រោងអចលនទ្រព្យនៅទីតាំងចម្បងអាចរក្សាស្ថានភាពនឹងនបាន និងអាចរក្សាតម្លៃរបស់អគារឬគម្រោងពួកគេបាន។ បន្ថែមពីនេះ របាយការណ៍ពិនិត្យឡើងវិញប្រចាំឆមាសទី១ របស់ក្រុមហ៊ុន CBRE បានបង្ហាញថាឆមាសទី២ នៃឆ្នាំ២០២៣ គឺជាពេលវេលាប្រឈមសម្រាប់ទាំងអ្នកលក់ និងជាឱកាសសម្រាប់អ្នកទិញ។ ខណៈបញ្ហាសេដ្ឋកិច្ចនៅតែបន្តមានសម្ពាធ ភាពស៊ាំនៃទីផ្សារត្រូវបានរំពឹងថានឹងត្រូវបានស្តារឡើងវិញបន្តិចម្តងៗ ជាមួយនឹងតម្រូវការនៃការជួល និងការផ្លាស់ប្តូរយុទ្ធសាស្ត្រនៅក្នុងអចលនទ្រព្យ។

## ផ្នែកទី ៥.-ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានព័ត៌មានគួរឱ្យកត់សម្គាល់ផ្សេងទៀតក្រៅពីព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍នេះទេ។

## ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

កាលបរិច្ឆេទៈ ថ្ងៃទី១៤ខែ សីហា ឆ្នាំ២០២៣

បានអាន និងឯកភាព

---

លោក នាង វិធី

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

# ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ និងសម្រាប់ដំណាច់
ការិយបរិច្ឆេទ ៣ខែ និង៦ខែដែលបានបញ្ចប់

# មាតិកា

| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១ |
| **ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** | |
| របាយការណ៍ស្ដីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល | ៦ - ៧ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៨ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ៩ - ១០ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១១ - ២៩ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ភ្ជាប់ជាមួយនឹងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដែលមានរបាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង៦ខែដែលបានបញ្ចប់ រួមទាំងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្ត ស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING Plc.
KINGDOM OF CAMBODIA

_______________________

**លោក នាង វិធី**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

Grant Thornton

# របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

## ជូនចំពោះភាគហ៊ុនិករបស់
## ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

យើងខ្ញុំបានធ្វើការត្រួតពិនិត្យទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍ចំណូលលម្អិតចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង៦ខែដែលបានបញ្ចប់ រួមទាំងសេចក្តីពន្យល់លើកំណត់សម្គាល់ ("ព័ត៌មានហិរញ្ញវត្ថុ")។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញជូននូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើសេចក្តីសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរជាចម្បងទៅកាន់បុគ្គលដែលទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុរួមទាំងការអនុវត្តតាមនីតិវិធីក្នុងការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងទៀត។ ការត្រួតពិនិត្យនេះមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ដូច្នេះហើយយើងខ្ញុំមិនធានាថា យើងខ្ញុំនឹងដឹងអំពីបញ្ហាសំខាន់ៗ ទាំងអស់ដែលអាចនឹងត្រូវបានកំណត់អត្តសញ្ញាណដូចការធ្វើសវនកម្មនោះទេ។ ហេតុនេះហើយ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

ផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានការជឿជាក់ថា ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មិនបានរៀបចំត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

Grant Thornton

**បញ្ហាផ្សេងៗ**

ព័ត៌មានប្រៀបធៀបក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺអាស្រ័យទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានធ្វើសវនកម្មរួច គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ព័ត៌មានប្រៀប ធៀបសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង ៦ខែដែលបានបញ្ចប់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ក្នុងរបាយការណ៍ចំណូលលម្អិត របាយការណ៍លំហូរសាច់ប្រាក់ រួមទាំងសេចក្តីពន្យល់ក្នុងកំណត់សម្គាល់ ត្រូវបានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្មឡើយ។

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | (បានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ - សុទ្ធ | ៦ | **៤.៩៥៣.៨៦៩** | **២០.២៨១.១៤០** | ៤.១០៣.៧៣៨ | ១៦.៨៩៥.០៨៩ |
| ទ្រព្យសកម្មអរូបី - សុទ្ធ | ៧ | **៤១.៣៣៨** | **១៦៩.២៣៨** | ៤៣.៧៤៥ | ១៨០.០៩៨ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ៨ | **១.៣០០** | **៥.៣២២** | ២០.១០០ | ៨២.៧៥២ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៤.៩៩៦.៥០៧** | **២០.៤៥៥.៧០០** | ៤.១៦៧.៥៨៣ | ១៧.១៥៧.៩៣៩ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៩ | **៤៣៥.៤៣៣** | **១.៧៨២.៦៦៣** | ២១.៤៦៤ | ៨៨.៣៦៧ |
| ប្រាក់តម្កល់ធានា | ១០ | **៦៥១.២១៨** | **២.៦៦៦.០៨៦** | ៥៩០.០៨០ | ២.៤២៩.៣៥៩ |
| គណនីពាណិជ្ជត្រូវទទួល | ១១ | **២.០៨៣.៩៦២** | **៨.៥៣១.៧៤០** | ៣.១៦៥.៧៧៣ | ១៣.០៣៣.៤៨៧ |
| សន្និធិ | ១២ | **១.០៨៨.២០៣** | **៤.៤៥៥.១០៣** | ១.២៧៤.១៣២ | ៥.២៤៥.៦០១ |
| ទ្រព្យសកម្មកិច្ចសន្យា | ១៤ | **៦.១៣៣.៦២០** | **២៥.១១១.០៤០** | ៤.៣៣៨.៧៧២ | ១៧.៨៦២.៧២៤ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | ២៥ | - | - | ១៣៦.២៧០ | ៥៦១.០២៤ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | ១៣ | **១.២៧៥.២៣៣** | **៥.២២០.៨០៤** | ១.០៦២.២៣៧ | ៤.៣៧៣.២៣០ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១១.៦៦៧.៦៦៩** | **៤៧.៧៦៧.៤៣៦** | ១០.៥៨៨.៧២៨ | ៤៣.៥៩៣.៧៩២ |
| **ទ្រព្យសកម្មសរុប** | | **១៦.៦៦៤.១៧៦** | **៦៨.២២៣.១៣៦** | ១៤.៧៥៦.៣១១ | ៦០.៧៥១.៧៣១ |
| **មូលធន** | | | | | |
| ដើមទុន | ១៥ | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ |
| បុព្វលាភដើមទុន | ១៥ | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ |
| ប្រាក់ចំណេញរក្សាទុក | | **១.៨៨០.៤៤៩** | **៧.៨០៩.១១៦** | ៨៨១.៣៩០ | ៣.៧១៨.៩៦៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរបម្រុងទុក | | - | **៤៤.២៥២** | - | ២២០.៣១៦ |
| **មូលធនសរុប** | | **៨.៦៥៣.៩៨៨** | **៣៥.៤២៩.៤២៥** | ៧.៦៥៤.៩២៩ | ៣១.៥១៥.៣៤១ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី - ដកចេញនូវចំណែករយៈពេលខ្លី | ១៦ | **១.៤៤៤.៤៧៥** | **៥.៩១៣.៦៨១** | ៥៩៩.៨៦៣ | ២.៤៦៩.៦៣៦ |
| **បំណុលរយៈពេលវែងសរុប** | | **១.៤៤៤.៤៧៥** | **៥.៩១៣.៦៨១** | ៥៩៩.៨៦៣ | ២.៤៦៩.៦៣៦ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | (បានធ្វើសវនកម្ម) | |
|---|---|---|---|---|---|
| | | **ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **បំណុលរយៈពេលខ្លី** | | | | | |
| បំណុលកិច្ចសន្យា | ១៤ | **១.១៧០.៩៦១** | **៤.៧៩៣.៩១៤** | ២.១០៥.២៥៤ | ៨.៦៦៧.៣៣១ |
| ប្រាក់កម្ចី | ១៦ | **៩០៤.៩៨៣** | **៣.៧០៥.០០០** | ៨៩៣.៧៨៣ | ៣.៦៧៩.៧០៥ |
| ឥណទានវិបារូបន៍ | ១៧ | **២.៨០៧.០៤២** | **១១.៤៩២.០៣០** | ២.៤១០.៩៨៤ | ៩.៩២៦.០២០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៨ | **១.៦៤៦.៧១០** | **៦.៧៤១.៦៣១** | ១.០៨០.២៤៤ | ៤.៤៤៧.៣៦៥ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៤(គ) | **៣៦.០១៧** | **១៤៧.៤៥៥** | ១១.២៥៤ | ៤៦.៣៣៣ |
| **បំណុលរយៈពេលខ្លីសរុប** | | **៦.៥៦៥.៧១៣** | **២៦.៨៨០.០៣០** | ៦.៥០១.៥១៩ | ២៦.៧៦៦.៧៥៤ |
| **បំណុលសរុប** | | ៨.០១០.១៨៨ | **៣២.៧៩៣.៧១១** | ៧.១០១.៣៨២ | ២៩.២៣៦.៣៩០ |
| **មូលធន និងបំណុលសរុប** | | **១៦.៦៦៤.១៧៦** | **៦៨.២២៣.១៣៦** | ១៤.៧៥៦.៣១១ | ៦០.៧៥១.៧៣១ |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| ចំណូល | ១៩ | **៦.៩៨០.២២៩** | **២៨.៦៣៩.៨៨០** | ២.៩៤៩.៤៤៩ | ១១.៩៧៤.៧៦៣ |
| ថ្លៃដើមសេវាកម្ម និងទំនិញបានលក់ | ២០ | **(៥.៩២១.៤៣៥)** | **(២៤.២៩៥.៦៤៨)** | (៣.៣៦៧.៨៧៥) | (១៣.៦៧៣.៥៧៣) |
| **ចំណេញ/(ខាត)ដុល** | | **១.០៥៨.៧៩៤** | **៤.៣៤៤.២៣២** | (៤១៨.៤២៦) | (១.៦៩៨.៨១០) |
| ចំណូលផ្សេងៗ - សុទ្ធ | ២២ | **៨.១៧០** | **៣៣.៥២២** | ៥.០២៦ | ២០.៤០៦ |
| ចំណាយប្រតិបត្តិការ | ២១ | **(៤៤៣.៥១៦)** | **(១.៨១៩.៧៤៦)** | (៣៨៩.៣១៧) | (១.៥៨០.៦២៧) |
| ចំណាយហិរញ្ញវត្ថុ | ២៣ | **(១១១.៨១៦)** | **(៤៥៨.៧៨១)** | (៧៤.២៦២) | (៣០១.៥០៤) |
| **ចំណេញ/(ខាត)មុនបង់ពន្ធ** | | **៥១១.៦៣២** | **២.០៩៩.២២៧** | (៨៧៦.៩៧៩) | (៣.៥៦០.៥៣៥) |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៤(ខ) | **(២៤.៧៦៣)** | **(១០១.៦០៣)** | (២៨.៨៥៨) | (១១៧.១៦៣) |
| **ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ** | | **៤៨៦.៨៦៩** | **១.៩៩៧.៦២៤** | (៩០៥.៨៣៧) | (៣.៦៧៧.៦៩៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | **(៣២១.៥៦២)** | - | (៩.០៥៩) |
| **ចំណូល/(ខាត)លម្អិតផ្សេងៗសរុប** | | **៤៨៦.៨៦៩** | **១.៦៧៦.០៦២** | (៩០៥.៨៣៧) | (៣.៦៨៦.៧៥៧) |

ចំណេញ/(ខាត)ក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញ/(ខាត)មូលដ្ឋានក្នុងមួយភាគហ៊ុន | **២៨** | **0,0២** | **0,0៩** | (0,0៤) | (0,១៩) |
| ចំណេញ/(ខាត)ថយចុះក្នុងមួយភាគហ៊ុន | **២៨** | **0,0២** | **0,0៩** | (0,0៤) | (0,១៩) |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៦ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៦ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| ចំណូល | ១៩ | **១០.៩៩០.២៦៤** | **៤៤.៩៩៤.១៤១** | ៦.៨៩៣.៣៧២ | ២៧.៩៨៧.០៩០ |
| ថ្លៃដើមសេវាកម្ម និងទំនិញបានលក់ | ២០ | **(៨.៨៦៣.៥៦៧)** | **(៣៦.២៨៧.៤៤៣)** | (៦.៣៩៧.៤៦៣) | (២៥.៩៧៣.៧០០) |
| **ចំណេញដុល** | | **២.១២៦.៦៩៧** | **៨.៧០៦.៦៩៨** | ៤៩៥.៩០៩ | ២.០១៣.៣៩០ |
| ចំណូលផ្សេងៗ - សុទ្ធ | ២២ | **៩.០៣៧** | **៣៦.៩៩៧** | ៨.២៤១ | ៣៣.៤៥៨ |
| ចំណាយប្រតិបត្តិការ | ២១ | **(៨០៨.៧៤១)** | **(៣.៣១០.៩៨៦)** | (៨១៤.២៨៦) | (៣.៣០៦.០០១) |
| ចំណាយហិរញ្ញវត្ថុ | ២៣ | **(២១៦.៤០៤)** | **(៨៨៥.៩៥៨)** | (១៩២.១៤៥) | (៧៨០.១០៩) |
| **ចំណេញ/(ខាត)មុនបង់ពន្ធ** | | **១.១១០.៥៨៩** | **៤.៥៤៦.៧៥១** | (៥០២.២៨១) | (២.០៣៩.២៦២) |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៤(ខ) | **(១១១.៥៣០)** | **(៤៥៦.៦០៤)** | (៣៤.៤៦៧) | (១៣៩.៩៣៦) |
| **ចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ** | | **៩៩៩.០៥៩** | **៤.០៩០.១៤៧** | (៥៣៦.៧៤៨) | (២.១៧៩.១៩៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(១៧៦.០៦៤)** | - | (៥.៣៧០) |
| **ចំណូល/(ខាត)លម្អិតផ្សេងៗសរុប** | | **៩៩៩.០៥៩** | **៣.៩១៤.០៨៣** | (៥៣៦.៧៤៨) | (២.១៨៤.៥៦៨) |

ចំណេញ/(ខាត)ក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ចំណេញ/(ខាត)មូលដ្ឋានក្នុងមួយភាគហ៊ុន | **២៨** | **០,០៥** | **០,២១** | (០,០២) | (០,១១) |
| ចំណេញ/(ខាត)ថយចុះក្នុងមួយភាគហ៊ុន | **២៨** | **០,០៥** | **០,២១** | (០,០២) | (០,១១) |

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល

| | ដើមទុន | | បុព្វលាភដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ បម្រុងទុកបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **៨៨១.៣៩០** | **៣.៧១៨.៩៦៨** | **២២០.៣១៦** | **៧.៦៥៤.៩២៩** | **៣១.៥១៥.៣៤១** |
| ចំណេញក្នុងការិយបរិច្ឆេទ | **-** | **-** | **-** | **-** | **៩៩៩.០៥៩** | **៤.០៩០.១៤៨** | **-** | **៩៩៩.០៥៩** | **៤.០៩០.១៤៨** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **-** | **-** | **-** | **-** | **-** | **(១៧៦.០៦៤)** | **-** | **(១៧៦.០៦៤)** |
| **សមតុល្យនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **១.៨៨០.៤៤៩** | **៧.៨០៩.១១៦** | **៤៤.២៥២** | **៨.៦៥៣.៩៨៨** | **៣៥.៤២៩.៤២៥** |
| (បានធ្វើសវនកម្ម) | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ២.២៨១.៦៦៤ | ៩.៤៤១.៨៨៧ | (១២៧.០៤៧) | ៩.០៥៥.២០៣ | ៣៦.៨៩០.៨៩៧ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) | - | (១.១៩២.១៤៦) | (៤.៨៧២.៣០០) |
| ភាគលាភ | - | - | - | - | (២០៨.១២៨) | (៨៥០.៦១៩) | - | (២០៨.១២៨) | (៨៥០.៦១៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ៣៤៧.៣៦៣ | - | ៣៤៧.៣៦៣ |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៤.៦១៥.៣៨៥ | ១៨.៧៩៦.៦៨៧ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | ៨៨១.៣៩០ | ៣.៧១៨.៩៦៨ | ២២០.៣១៦ | ៧.៦៥៤.៩២៩ | ៣១.៥១៥.៣៤១ |

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៦ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ ៦ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណូល | | **១.១១០.៥៨៩** | **៤.៥៤៦.៧៥១** | (៥០២.២៨១) | (២.០៣៩.២៦២) |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យរូបី និងអរូបី | ៦ និង ៧ | **៩៩.៧៩៤** | **៤០៨.៥៥៧** | ៩៦.៤០៨ | ៣៩១.៤១៦ |
| ខាតលើការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ និង ទ្រព្យសកម្មអរូបី | ៦ | **៤.២៣៧** | **១៧.៣៤៦** | - | - |
| ចំណូលការប្រាក់ | ២២ | **(៦៨៥)** | **(២.៨០៤)** | (២.៨៩៨) | (១១.៧៦៦) |
| ចំណាយហិរញ្ញវត្ថុ | ២៣ | **២១៦.៤០៤** | **៨៨៥.៩៥៨** | ១៩២.១៤៥ | ៧៨០.១០៩ |
| ពន្ធលើប្រាក់ចំណូល | ២៤ | - | - | ១៤.៩៩០ | ៦០.៨៥៩ |
| **ចំណេញ/(ខាត)ប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **១.៤៣០.៣៣៩** | **៥.៨៥៥.៨០៨** | (២០១.៦៣៦) | (៨១៨.៦៥៤) |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| បម្រែបម្រួលសុទ្ធក្នុង៖ | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | | **(១.៧៩៤.៨៤៨)** | **(៧.៣៤៨.១០៨)** | ១.១៦៤.៦៨៤ | ៤.៧២៨.៦១៧ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | | **(២១២.៩៩៦)** | **(៨៧២.០០៦)** | ៧០.៥២០ | ២៨៦.៣១១ |
| សមតុល្យដែលភាគហ៊ុនិកជំពាក់ | | **១៣៦.២៧០** | **៥៥៧.៨៨៩** | - | - |
| សន្និធិ - សុទ្ធ | | **១៨៥.៩២៩** | **៧៦១.១៩៣** | ៧៩២.០៣១ | ៣.២១៥.៦៤៦ |
| ប្រាក់តម្កល់ធានា | | **(៦១.១៣៨)** | **(២៥០.២៩៩)** | (៤១៥.០០០) | (១.៦៨៤.៩០០) |
| គណនីពាណិជ្ជត្រូវទទួល | | **១.០៨១.៨១១** | **៤.៤២៨.៩៣៤** | ២.៣៨៤.២៩០ | ៩.៦៨០.២១៧ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | | **១៨.៨០០** | **៧៦.៩៦៧** | (៥.០៥០) | (២០.៥០៣) |
| ឥណទានវិបារូបន៍ | | **៣៩៦.០៥៨** | **១.៦២១.៤៦១** | (៧៥៥.៧៥៧) | (៣.០៦៨.៣៧៣) |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **៥៦៦.៤៦៦** | **២.៣១៩.១១២** | (២៤១.៨៥៩) | (៩៨១.៩៤៨) |
| បំណុលកិច្ចសន្យា | | **(៩៣៤.២៩៣)** | **(៣.៨២៤.៩៩៦)** | ៧៧០.៧៣៨ | ៣.១២៩.១៩៦ |
| **សាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | **៨១២.៣៩៨** | **៣.៣២៥.៩៥៥** | ៣.៥៦២.៦៩៧ | ១៤.៤៦៤.៥៤៨ |
| ការប្រាក់បានទទួល | | **៦៨៥** | **២.៨០៤** | ២.៨៩៨ | ១១.៧៦៦ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ២៤(គ) | **(៨៦.៧៦៧)** | **(៣៥៥.២២៤)** | (៧៧.៤២២) | (៣១៦.៤២៤) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | **៧២៦.៣១៦** | **២.៩៧៣.៥៣៥** | ៣.៤៨៨.១៧៣ | ១៤.១៦១.៩៨១ |

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល (ត)

| | | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)<br>សម្រាប់ដំណាច់ការិយបរិច្ឆេទ<br>៦ខែ ដែលបានបញ្ចប់<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | | (មិនបានត្រួតពិនិត្យ និងមិនបានធ្វើសវនកម្ម)<br>សម្រាប់ដំណាច់ការិយបរិច្ឆេទ<br>៦ខែ ដែលបានបញ្ចប់<br>ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ ៣) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | **(៩៥៤.៧០៥)** | **(៣.៩០៨.៥៦៦)** | (៧០៤.៤៧៦) | (២.៨៦០.១៧៣) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ និង ៧ | **២.៩៥០** | **១២.០៧៧** | - | - |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(៩៥១.៧៥៥)** | **(៣.៨៩៦.៤៨៩)** | (៧០៤.៤៧៦) | (២.៨៦០.១៧៣) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការទទួលប្រាក់កម្ចី | ១៦ | **២.៩៦៨.៩១៤** | **១២.១៥៤.៧៣៤** | ២.៨០០.៣៨៥ | ១១.៣៦៩.៥៦៣ |
| ការទូទាត់ប្រាក់កម្ចី | ១៦ | **(២.១១៣.១០២)** | **(៨.៦៥១.០៤០)** | (៥.០៩៨.៤៣០) | (២០.៦៩៩.៦២៦) |
| ការទូទាត់ការប្រាក់ | ១៦ | **(២១៦.៤០៤)** | **(៨៨៥.៩៥៨)** | (១៩០.៥១០) | (៧៧៣.៤៧១) |
| ការទូទាត់ភាគលាភ | | - | - | (២០៨.១២៨) | (៨៤៥.០០០) |
| ការទូទាត់បំណុលភតិសន្យា | | - | - | (៣៣.៦០០) | (១៣៦.៤១៦) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើ)ក្នុងសកម្មភាពហិរញ្ញវត្ថុ** | | **៦៣៩.៤០៨** | **២.៦១៧.៧៣៦** | (២.៧៣០.២៨៣) | (១១.០៨៤.៩៥០) |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ ក្នុងអំឡុងការិយបរិច្ឆេទ** | | **៤១៣.៩៦៩** | **១.៦៩៤.៧៨៣** | ៥៣.៤១៤ | ២១៤.៧៦៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងអំឡុង ដើមការិយបរិច្ឆេទ | | **២១.៤៦៤** | **៨៨.៣៦៧** | ២២៥.១១៩ | ៩១៧.១៣៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(៤៨៧)** | - | ១.៧២៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | | **៤៣៥.៤៣៣** | **១.៧៨២.៦៦៣** | ២៧៨.៥៣៣ | ១.១៣៣.៦២៩ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ១. អំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ មានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ នៅក្រសួងពាណិជ្ជកម្ម។ ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ដែលអនុញ្ញាតក្រុមហ៊ុនឱ្យដំណើរការអាជីវកម្មសម្រាប់រយៈពេល៩៩ ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មគោលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅក្បាលដីលេខ១២៩៨ ផ្លូវបេតុង ភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ អនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលអាសយដ្ឋានចុះបញ្ជីរបស់ខ្លួន។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គិភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអគារ។

នៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២១ ក្រុមហ៊ុនត្រូវបានចុះបញ្ជីដោយជោគជ័យនៅលើទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមានចំនួន ៦.៤៦១.៥៣៨ ហ៊ុន ជាមួយតម្លៃចារឹក ១០០០ រៀល ឬ ០.២៥ ដុល្លារអាមេរិកក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល ឬ ០.៥៨០ ដុល្លារក្នុងមួយហ៊ុន។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ក្រុមហ៊ុនមាននិយោជិតចំនួន ៨៧៧ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៖ មានចំនួន១.១១២ នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង៦ខែ ដែលបានបញ្ចប់នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល។ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលកំណត់សម្គាល់ទាំងអស់ដូចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចប្រចាំឆ្នាំនោះទេ។ ដូច្នេះ របាយការណ៍នេះត្រូវអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គោលនយោបាយគណនេយ្យសំខាន់ៗ ដែលប្រើក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺស្របតាមគោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក("USD") គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិក ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងនៃការវាស់វែង និងការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយវត្ថុបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកក្នុងអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ កំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក នាកាលបរិច្ឆេទរបាយការណ៍ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃរបាយការណ៍នោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាខ្មែររៀល បានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានធ្វើឡើង គឺដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ("NBC")៖

| | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ |
|---|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* ៣ខែ | **៤.១៣០** | ៤.០៦០ | មិនមាន |
| អត្រាប្តូរប្រាក់ជាមធ្យម* ៦ខែ | **៤.០៩៤** | ៤.០៦០ | មិនមាន |
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.០៩៤** | ៤.០៧០ | ៤.១១៧ |

*អត្រាប្តូរប្រាក់ជាមធ្យម គឺត្រូវបានគណនាដោយប្រើប្រាស់អត្រាប្រចាំថ្ងៃរបស់ធនាគារជាតិ នៃ កម្ពុជាក្នុងអំឡុងការិយបរិច្ឆេទ

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនត្រូវបានបកស្រាយថា ជាតំណាងនៃប្រាក់ដុល្លារអាមេរិក ឬដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

### ប្រតិបត្តិការ និងសមតុល្យនៃរូបិយប័ណ្ណបរទេស

សមាសធាតុមិនមែនជារូបិយវត្ថុ គឺមិនត្រូវបានប្តូរឡើងវិញនៅចុងការិយបរិច្ឆេទ និងត្រូវបានវាស់វែងតាមថ្លៃដើមប្រវត្តិសាស្ត្រ (បានប្តូររូបិយប័ណ្ណដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ) លើកលែងសម្រាប់សមាសធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ដែលត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ

